# សាលាបឋមសិក្សា គឺជាក្តីសង្ឃឹមរបស់ភូមិ

*អត្ថបទពិពណ៌នាអំពីការអប់រំថ្នាក់បឋមសិក្សា និងការជួសជុលអគារសាលារៀន :*

*រៀបចំដោយបុគ្គលិកគំរោងរបស់អង្គការ LWF  កម្ពុជា ប្រចាំខេត្តបាត់ដំបង កែសំរួលដោយ Marcus Busch*

*ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧*

*អ្នកអាន:  សមាគមគ្រីស្តសាសនាលូថេរ៉ានប្រចាំប្រទេសជប៉ុន (JELA)*



Tang You Primary School



Students sit on the floor to study

ស្វាគមន៏ចំពោះការអញ្ជើញមកដល់ភូមិតាំងយូ ស្ថិតនៅភាគបស្ចឹមនៃប្រទេសកម្ពុជា ដែលនៅទីនេះ អង្គការលូថេរ៉ានបំរើពិភពលោកប្រចាំនៅកម្ពុជា បានអនុវត្តការងារយ៉ាងសកម្មតាំងពីឆ្នាំ ១៩៩៦ ។ ជាភូមិមួយដែលស្ថិតនៅឯកោរ ដោយមានប្រជាជន ៧៥១ នាក់ (១១៤ គ្រួសារ) នៅភាគពាយ័ព្យនៃខេត្តបាត់ដំបង គេអាចធ្វើដំណើរទៅកាន់ភូមិ តាំងយូ បានដោយលំបាកនៅរដូវវស្សា (ខែមិថុនាដល់ខែវិច្ឆិកា) ។ ជាមួយនឹងអត្រាអនក្ខរភាព ៦៥% (៧២% ចំពោះបុរស ៥៨% ចំពោះស្ត្រី) អ្នកចេះអក្សរនៅក្នុងភូមិ គឺមានចំនួន ៩ % ស្ថិតនៅក្រោមអត្រាជាមធ្យមនៅទូទាំងប្រទេស ។ ឪពុក ម្តាយនៅក្នុងភូមិនេះ ចង់បានអ្នកចេះអក្សរឱ្យមានចំនួនច្រើនឡើងនៅក្នុងចំណោមក្មេងជំនាន់ក្រោយ ។

**ទីកន្លែងរឿង:** ភូមិតាំងយូ ឃុំអូដា ស្រុកកំរៀង ខេត្តបាត់ដំបង

នៅពេលសម្ពោធការសាងសង់សាលាបឋមសិក្សាតាំងយូ ដែលគាំទ្រដោយ LWF-C និង JELA យើងបានចុះទៅភូមិ ដើម្បីនិយាយជាមួយប្រជាជនជាច្រើនដែលមានការពាក់ព័ន្ធនឹងជីវិតរបស់សាលារៀន ។



លោក **សូ ភាព** អាយុ ៣៦ ឆ្នាំ ជាមេភូមិ មានប្រសាសន៍ថា " ខ្ញុំមានក្តីរីករាយណាស់ និងមានការពេញចិត្តជាខ្លាំងដោយភូមិរបស់ខ្ញុំ មានសាលាបឋមសិក្សាប្រកបដោយគុណភាព ដែលក្មេងៗ អាចមករៀនបាន ។" លោក ភាព សង្ឃឹមថា ដំណើរការរបស់សាលារៀន នឹងលែងផ្អាកនៅរដូវវស្សាទៀតហើយ ។ គាត់បន្តថា " មុនពេលកសាងអគារនេះ ខ្ញុំមានការព្រួយបារម្ភជាខ្លាំងអំពីសន្តិសុខរបស់កុមារ ដែលមករៀននៅក្នុងអគារចាស់ ពីព្រោះខ្ញុំគិតថា វានឹងបាក់នៅថ្ងៃណាមួយ ។ ប៉ុន្តែនៅពេលនេះ យើងមានសុវត្ថិភាព ហើយអ្នកភូមិ មានការពេញចិត្តជាខ្លាំង ។"

គាត់បន្ថែមថា ទោះបីជាអគារសិក្សាថ្មី អាចទទួលកុមារគ្រប់អាយុចូលរៀនទាំងអស់នៅក្នុងភូមិក្តី ក៏សាលារៀននេះ មិនមានតុសិស្ស ឬតុគ្រូឡើយ ។ នៅពេលនេះ សិស្សអង្គុយផ្ទាល់ឥដ្ឋ នៅក្នុងថ្នាក់រៀន ។

ដោយការអរគុណដល់អ្នកផ្តល់ជំនួយទាំងអស់ដែលបានគាំទ្រការសាងសង់អគារសិក្សា នៅពេលនេះ លោកភាព ស្នើសុំអ្នកផ្តល់ជំនួយឱ្យជួយផ្តល់តុ កៅអីដល់សាលារៀន។

យើងបានបន្តទៅជួបលោក **ម៉ុក រឿន** អាយុ ៥៥ ឆ្នាំ ជាសមាជិកគណៈកម្មការសាលារៀននិងលោក ប៉ែក សឿន អាយុ ៥៣ ឆ្នាំជានាយកសាលាបឋមសិក្សា។ ពួកគាត់ មានប្រសាសន៍ថា នៅឆ្នាំ ២០០៦ អ្នកភូមិបញ្ជូនកូនរបស់គាត់ទៅសាលារៀននៅខាងក្រៅសហគមន៍ ដែលស្ថិតនៅឆ្ងាយពីផ្ទះ។ ឪពុក ម្តាយមួយចំនួន បានបញ្ឈប់កូន របស់គាត់មិនឱ្យទៅរៀនទាំងអស់គ្នា ដោយសារអគារសាលារៀនចាស់មានសភាពទ្រុឌទ្រោម។ ប៉ុន្តែ សំរាប់ឆ្នាំសិក្សា ២០០៧ ចាប់តាំងពីការសាងសង់សាលានេះឡើងវិញ ចំនួនសិស្សចូលរៀនមានការកើនឡើងជាខ្លាំង បើប្រៀបធៀបនឹងឆ្នាំ ២០០៦។



ដើម្បីកែលំអគុណភាពនៃការសិក្សា លោកនាយកសាលា ប៉ែន សឿន មានប្រសាសន៍ថា គាត់នឹងពង្រឹងសមត្ថភាពគ្រូបង្រៀន។ លោក ម៉ុក រឿន បន្ថែមថា គាត់នឹងកៀងគរសហគមន៍អោយថែរក្សាអគារសាលារៀន ដើម្បីអោយអគារនេះ នៅស្ថិតស្ថេរបានយូរអង្វែង។

ដូចគ្នានឹងលោក សូ ភាព ដែរ លោក រឿន និង លោក សឿន ស្នើសុំគ្រឿងបរិក្ខា ដូចជា តុនិងកៅអី សំរាប់សិស្ស និងគ្រូបង្រៀន និងទ្វារសាលារៀន។



កុមារី **ប្រាង ស្រីអូន** អាយុ ១២ ឆ្នាំ ជាសិស្សថ្នាក់ទី ៤ ប្រាប់យើងថា "ការធ្វើជាអ្នកបកប្រែភាសាអង់គ្លេស គឺជាក្តីសុបិន្តរបស់ខ្ញុំ។ ខ្ញុំនឹងប្រឹងប្រែងរៀនសូត្រ ដើម្បីអោយសុបិន្តនេះក្លាយទៅជាការពិត។"

"ខ្ញុំមានក្តីរីករាយណាស់ដែលខ្ញុំមានអគារល្អ ដើម្បីរៀនសូត្រ។ ពេលខ្ញុំរៀនសូត្រនៅក្នុងអគារចាស់ ខ្ញុំមានអារម្មណ៍ភ័យខ្លាច ពីព្រោះវាស្ទើរតែបាក់ធ្លាក់។ នៅពេលមានភ្លៀង ការរៀនសូត្រ ត្រូវបញ្ឈប់។ យើងជាសិស្ស ត្រូវទៅឈរនៅកន្លែងដែលមិនត្រូវទឹកភ្លៀង។"

ស្រីអូន បន្តថា "អគារសិក្សានេះ ល្អណាស់ ប៉ុន្តែខ្ញុំចង់បានតុសំរាប់សិស្ស កៅអីសំរាប់លោកគ្រូ សួនច្បារ ទីធ្លាសំរាប់លេងកីឡា របងព័ទ្ធជុំវិញសាលារៀន និងទ្វារដូចសាលាដទៃទៀត។"

សិស្សនៅសាលាបឋមសិក្សាតាំងយូ

| ថ្នាក់ | ចំនួនសិស្សសរុប | សិស្សស្រី | |
|---|---|---|---|
| 1 | 48 | 21 | 44% |
| 2 (2 ថ្នាក់) | 64 | 34 | 53% |
| 3 | 35 | 16 | 46% |
| 4 | 30 | 17 | 57% |
| 5 | 37 | 16 | 43% |
| 6 | 33 | 14 | 42% |
| | 247 | 118 | 48% |

បុគ្គលិក

នាយកសាលា

គ្រូថ្នាក់ទី ១និងទី ២

គ្រូថ្នាក់ទី ៣

គ្រូថ្នាក់ទី ៤

គ្រូថ្នាក់ទី ៥និងទី ៦

សរុបៈ គ្រូ ៥ នាក់